# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សេចក្តីសង្ខេបគោលនយោបាយ
លេខ ០៤ | ខែមីនា ឆ្នាំ២០២៦

## វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូបរបស់កម្ពុជា ក្រោមសម្ពាធពន្ធគយ និងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចៈ ហានិភ័យនៃភាពប្រកួតប្រជែង និងអាទិភាពគោលនយោបាយ

### ចំណុចគន្លឹះ

**បញ្ហាប្រឈម**

- វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (GFT) របស់កម្ពុជា កំពុងឈានចូលក្នុងបរិយាកាសពាណិជ្ជកម្មដែលមានតម្រូវការកាន់តែតឹងរ៉ឹង ខណៈដែលកម្ពុជាខិតជិតដល់ការចាកចេញពី ក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDC)។ ហានិភ័យចម្បងសម្រាប់រយៈពេលមធ្យម គឺការរឹតបន្តឹងលើវិធានដើមកំណើតទំនិញក្រោយឆ្នាំ២០២៩។
- កត្តារចនាសម្ព័ន្ធផ្សេងទៀត រួមមាន គម្លាតជំនាញ និងផលិតភាព ការកើនឡើងនៃថ្លៃថាមពល និងការអនុលោមតាមបទប្បញ្ញត្តិ ព្រមទាំងកម្រិតមានកំណត់នៃដីឧស្សាហកម្ម ដែលមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិនិយោគលើដើមខ្សែច្រវាក់ផលិតកម្ម។

**អនុសាសន៍**

- កម្ពុជាគួរឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើ តាមរយៈយុទ្ធសាស្ត្រឧស្សាហកម្មដែលផ្តោតលើអាទិភាពចំនួន ៥ រួមមាន៖ (១) ការអនុវត្តការបូកសរុបតម្រូវការរួម ដើម្បីប៉ាន់ស្មានបរិមាណអប្បបរមានៃការធានាទិញក្រណាត់ ក្នុងអំឡុងពេលអន្តរកាល (២) កំណត់និងអភិវឌ្ឍតំបន់ឧស្សាហកម្មវាយនភណ្ឌ (៣) ពន្លឿនការអភិវឌ្ឍជំនាញ (៤) កាត់បន្ថយថ្លៃដឹកជញ្ជូន និងថ្លៃថាមពល និង (៥) ជំរុញការទូតពាណិជ្ជកម្មឱ្យកាន់តែសកម្ម តាមរយៈការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយដៃគូសំខាន់ៗ។

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

☎ ០២៣ ៨៨៤ ៣៧៥/០២៣ ៨៨៤ ៣៧៦

អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

info@mlvt.gov.kh

### សេចក្តីផ្តើម

វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប (GFT) នៅតែជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនាំចេញរបស់កម្ពុជា បើទោះបីជាបរិយាកាសពាណិជ្ជកម្មអន្តរជាតិកាន់តែមានភាពស្មុគស្មាញ និងភាពមិនប្រកដប្រជាក៏ដោយ។ ក្នុងចន្លោះឆ្នាំ ២០២១ ដល់ ២០២៥ ការនាំចេញសរុបរបស់កម្ពុជាបានងើបឡើងវិញយ៉ាងខ្លាំង និងបានឈានដល់កម្រិតខ្ពស់បំផុតក្នុងឆ្នាំ ២០២៥។ ក្នុងសន្ទុះកំណើននេះ ផលិតផល GFT នៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញចំណូលនាំចេញ និងបានបង្ហាញពីភាពធន់ ទោះបីជាមានការកើនឡើងនៃថ្លៃដើមផលិតកម្ម ភាពមិនច្បាស់លាស់នៃរបបពន្ធគយ និងការរំពឹងទុកនៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ក៏ដោយ។ នៅឆ្នាំ ២០២៥ ការនាំចេញផលិតផល GFT សម្រេចបានប្រមាណ ១៦ ពាន់លានដុល្លារអាម៉េរិក ដែលកើនឡើង ១៦,៣% ធៀបនឹងចំនួន ១៣,៧ ពាន់លានដុល្លារអាម៉េរិកក្នុងឆ្នាំ ២០២៤។ មូលដ្ឋានផលិតកម្មរបស់កម្ពុជា នៅតែមានឧត្តមភាពប្រកួតប្រជែង និងបានចាក់ឫសយ៉ាងរឹងមាំក្នុងខ្សែច្រវាក់តម្លៃសកល។

**រូបទី១៖** ការនាំចេញផលិតផលសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ និងកាបូប របស់កម្ពុជា ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៥




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០២៥*

ទោះជាយ៉ាងណាក៏ដោយ កំណើននៃការនាំចេញយ៉ាងខ្លាំងក្លានាពេលថ្មីៗនេះ មិនគួរត្រូវបានចាត់ទុកជាភស្តុតាង ដែលបង្ហាញថាភាពប្រកួតប្រជែងរបស់វិស័យ GFT ក្នុងរយៈពេលមធ្យម មានសុវត្ថិភាពនោះទេ ព្រោះថាការផ្លាស់ប្តូរនៃវិធានដើមកំណើតទំនិញក្រោយឆ្នាំ ២០២៩ នឹងសាកល្បងលើការពឹងផ្អែកខ្លាំងរបស់វិស័យនេះទៅលើក្រណាត់នាំចូល និងធាតុចូលវាយនភណ្ឌផ្សេងៗទៀត។ ក្នុងពេលដូចគ្នា កម្ពុជាក៏បានរក្សាលទ្ធផលនាំចេញល្អនៅទីផ្សារសំខាន់ៗផងដែរ។ នៅឆ្នាំ២០២៥ ការនាំចេញផលិតផល GFT ទៅសហភាពអឺរ៉ុបកើនឡើង ១០,៥ ភាគរយ ខណៈការនាំចេញទៅសហរដ្ឋអាមេរិកកើនឡើង ២៦,៣ ភាគរយ (សូមមើលតារាងទី ១)។

**តារាងទី១៖** បម្រែបម្រួលតម្លៃនាំចេញរវាងឆ្នាំ ២០២៤ និង ២០២៥

| ប្រទេស | ២០២៤ | | ២០២៥ | | ភាគរយប្រែប្រួល |
|---|---|---|---|---|---|
| | តម្លៃ | ចំណែក | តម្លៃ | ចំណែក | |
| **ការនាំចេញសរុប** | **២៦ ៦៦៥** | **១០០,០%** | **៣១ ២៨១** | **១០០,០%** | **១៧,៣%** |
| អាស៊ាន | ៥ ០៧១ | ១៩,០% | ៥ ៦៧៤ | ១៨,១% | ១១,៩% |
| អឺរ៉ុប ២៧ | ៤ ៤១២ | ១៦,៥% | ៥ ០០៨ | ១៦,០% | ១៣,៥% |
| អាមេរិក | ៩ ៩១៦ | ៣៧,២% | ១២ ៧៣១ | ៤០,៧% | ២៨,៤% |
| ចិន | ១ ៧៥០ | ៦,៦% | ១ ៦៨៧ | ៥,៤% | -៣,៦% |
| ជប៉ុន | ១ ៤០៩ | ៥,៣% | ១ ៥៧៦ | ៥,០% | ១១,៩% |
| អង់គ្លេស | ៩៥៩ | ៣,៦% | ១ ០១៥ | ៣,២% | ៥,៩% |
| ផ្សេងៗ | ៣ ១៤៨ | ១១,៨% | ៣ ៥៩១ | ១១,៥% | ១៤,០% |
| **ការនាំចេញ GFT** | **១៣ ៧៤២** | **៥១,៥%** | **១៥ ៩៨៩** | **៥១,១%** | **១៦,៣%** |
| អាស៊ាន | ២២៦ | ១,៦% | ៣០៥ | ១,៩% | ៣៤,៧% |
| អឺរ៉ុប ២៧ | ៣ ៨៤០ | ២៧,៩% | ៤ ២៤៤ | ២៦,៥% | ១០,៥% |
| អាមេរិក | ៥ ៣០៧ | ៣៨,៦% | ៦ ៧០២ | ៤១,៩% | ២៦,៣% |
| ចិន | ៣១៥ | ២,៣% | ៣៤៣ | ២,១% | ៨,៨% |
| ជប៉ុន | ១ ១១២ | ៨,១% | ១ ២២៥ | ៧,៧% | ១០,២% |
| អង់គ្លេស | ៨៥៩ | ៦,៣% | ៨៩៥ | ៥,៦% | ៤,២% |
| ផ្សេងៗ | ២ ០៨៤ | ១៥,២% | ២ ២៧៦ | ១៤,២% | ៩,២% |
| **ផលិតផលក្រៅពី GFT** | **១២ ៩២២** | **៤៨,៥%** | **១៥ ២៩៣** | **៤៨,៩%** | **១៨,៣%** |
| អាស៊ាន | ៤ ៨៤៥ | ៣៧,៥% | ៥ ៣៧០ | ៣៥,១% | ១០,៨% |
| អឺរ៉ុប ២៧ | ៥៧២ | ៤,៤% | ៧៦៤ | ៥,០% | ៣៣,៦% |
| អាមេរិក | ៤ ៦០៩ | ៣៥,៧% | ៦ ០២៨ | ៣៩,៤% | ៣០,៨% |
| ចិន | ១ ៤៣៥ | ១១,១% | ១ ៣៤៤ | ៨,៨% | -៦,៤% |
| ជប៉ុន | ២៩៧ | ២,៣% | ៣៥១ | ២,៣% | ១៨,៤% |
| អង់គ្លេស | ១០០ | ០,៨% | ១២០ | ០,៨% | ២០,៧% |
| ផ្សេងៗ | ១ ០៦៥ | ៨,២% | ១ ៣១៥ | ៨,៦% | ២៣,៥% |

*សម្គាល់៖ តម្លៃ គិតជាលានដុល្លារអាមេរិក*

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០២៥*

ទីផ្សារសហភាពអឺរ៉ុបគ្របដណ្តប់ ២៦,៥ ភាគរយ នៃទំហំនាំចេញ GFT សរុបរបស់កម្ពុជា ខណៈដែលទីផ្សារសហរដ្ឋអាមេរិកមានចំណែករហូតដល់ ៤១,៩ ភាគរយ (សូមមើលរូបភាពទី២)។ និន្នាការនេះសបញ្ជាក់ថា កម្ពុជានៅតែបន្តរក្សាបាននូវឧត្តមភាពទីផ្សាររបស់ខ្លួន មិនត្រឹមតែតាមរយៈការប្រកួតប្រជែងថ្លៃដើមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតាមរយៈទំនុកចិត្តពីអ្នកបញ្ជាទិញ ការអនុលោមតាមបទដ្ឋានអន្តរជាតិ និងនិរន្តរភាពនៃផលិតកម្ម ក្នុងបរិបទនៃលក្ខខណ្ឌពាណិជ្ជកម្មដែលកំពុងផ្លាស់ប្តូរ។ ទោះជាយ៉ាងនេះក្តី ភាពធន់ដែលសម្រេចបាននាពេលថ្មីៗនេះ គឺជាចំណុចខ្លាំងដ៏សំខាន់ ប៉ុន្តែវាមិនទាន់គ្រប់គ្រាន់សម្រាប់ជំនួសឱ្យតម្រូវការនៃការធ្វើទំនើបកម្មរចនាសម្ព័ន្ធនោះឡើយ ខណៈកម្ពុជាកំពុងរៀបចំខ្លួនចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ដែលនឹងត្រូវប្រឈមមុខនឹងបទប្បញ្ញត្តិពាណិជ្ជកម្មកាន់តែតឹងរ៉ឹង។

**រូបភាពទី២៖** ចំណែកទីផ្សារនៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូបរបស់កម្ពុជា ទៅកាន់ទីផ្សារពិភពលោក ចន្លោះឆ្នាំ២០២០-២០២៥




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០២៥*

## ហេតុអ្វីបានជាវិស័យ GFT នៅតែមានសារៈសំខាន់

វិសាលភាពនៃសារៈសំខាន់របស់វិស័យ GFT មានសក្តានុពលធំធេងលើសពីចំណូលពីការនាំចេញ។ នៅឆ្នាំ២០២៥ ការនាំចេញសរុបរបស់កម្ពុជាបានឈានដល់ប្រមាណ ៣១,៣ ពាន់លានដុល្លារអាមេរិក ដែលក្នុងនោះវិស័យ GFT រួមចំណែករហូតដល់ ១៦,០ ពាន់លានដុល្លារអាមេរិក ឬស្មើនឹង ៥១,១ ភាគរយ (សូមមើលរូបភាពទី៣)។ ហេតុដូច្នេះ ហានិភ័យនៃការធ្លាក់ចុះណាមួយនៃភាពប្រកួតប្រជែងក្នុងវិស័យ GFT នឹងជះឥទ្ធិពលជាអវិជ្ជមានយ៉ាងច្រើនដល់ចំណូលរូបិយប័ណ្ណបរទេស ស្ថិរភាពការងារក្នុងប្រព័ន្ធ ទំនុកចិត្តរបស់វិនិយោគិន និងយុទ្ធសាស្ត្រឧស្សាហូបនីយកម្មជារួមរបស់កម្ពុជា។ វិស័យ GFT មិន

ត្រឹមតែជាក្បាលម៉ាស៊ីនរុញច្រានកំណើនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាគ្រឹះដ៏សំខាន់សម្រាប់ការបណ្តុះបណ្តាលជំនាញឧស្សាហកម្ម និងការបង្កើនសមត្ថភាពរបស់កម្ពុជា ក្នុងការឈានឡើងទៅកាន់ខ្សែច្រវាក់តម្លៃតំបន់ និងសកលឱ្យកាន់តែខ្ពស់ជាងមុន។

ក្នុងពេលជាមួយគ្នានេះដែរ ស្ថានភាពពន្ធគយរបស់កម្ពុជា មិនមែនសុទ្ធតែមិនអំណោយផលនោះទេ។ អត្រាពន្ធ ១៩ ភាគរយ បានដាក់កម្ពុជាឱ្យស្ថិតក្នុងកម្រិតប្រហាក់ប្រហែលនឹងដៃគូប្រកួតប្រជែង ក្នុងតំបន់មួយចំនួនរួមមាន ប្រទេសថៃ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងហ្វីលីពីន ហើយទាបជាងដៃគូប្រកួតប្រជែងមួយចំនួនទៀត ដូចជា បង់ក្លាដែស មីយ៉ាន់ម៉ា និងឥណ្ឌា។ កត្តានេះមិនបានលុបបំបាត់ហានិភ័យនៃភាពប្រកួតប្រជែងនោះទេ ប៉ុន្តែវាបង្ហាញថា កម្ពុជានៅតែមានលទ្ធភាពប្រកួតប្រជែង ប្រសិនបើខ្លួនអាចលើកកម្ពស់ផលិតភាព ពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងស្រុកឱ្យកាន់តែរឹងមាំ និងកាត់បន្ថយសម្ពាធថ្លៃដើមក្នុងស្រុក។

**រូបភាពទី៣៖** តម្លៃនាំចេញសរុបរបស់កម្ពុជា តាមប្រភេទផលិតផល ពីឆ្នាំ ២០២០-២០២៥




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០២៥*

## ហានិភ័យរចនាសម្ព័ន្ធក្រោមសម្ពាធពន្ធគយ និងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច

**ហានិភ័យជាយុទ្ធសាស្ត្របំផុតក្នុងរយៈពេលមធ្យម** គឺការរឹតបន្តឹងវិធានដើមកំណើតទំនិញ (Rules of Origin) ក្រោយឆ្នាំ ២០២៩។ បន្ទាប់ពីការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDC) កម្ពុជានឹងត្រូវអនុវត្តតាមលក្ខខណ្ឌដើមកំណើតទំនិញ ដែលតឹងរ៉ឹងជាងមុន ដែលនឹងធ្វើឱ្យការបន្តពឹងផ្អែកខ្លាំងលើវត្ថុធាតុដើមនាំចូលក្លាយជាហានិភ័យដ៏ចម្បង។ ការពឹងផ្អែកស្ទើរតែទាំងស្រុងលើគ្រឿងបន្លាស់នាំចូល នឹងមិនអាចធានាឱ្យកម្ពុជាទទួលបាននូវការអនុគ្រោះពាណិជ្ជកម្មសម្រាប់ការនាំចេញក្នុងបរិមាណដ៏ច្រើនដូចមុនទៀតនោះឡើយ។ ដោយសារបច្ចុប្បន្ន វិស័យនេះនៅតែពឹងផ្អែកខ្លាំងលើការនាំចូលក្រណាត់ពីប្រទេសចិន និងវៀតណាម ផលិតផលនាំចេញភាគច្រើនអាចនឹងមិនឆ្លើយតបតាមបទប្បញ្ញត្តិនៃវិធានដើមកំណើតទំនិញថ្មី លុះត្រាតែកម្ពុជាអាចអភិវឌ្ឍសមត្ថភាពផលិតក្នុងស្រុកលើការត្បាញ ការចាក់ ការជ្រលក់ពណ៌ និងការកែច្នៃសម្រេច។ នេះគឺជាបញ្ហាប្រឈមផ្នែករចនាសម្ព័ន្ធដ៏ចម្បងបំផុត ដែលទាមទារឱ្យមានការដោះស្រាយជាបន្ទាន់ ស្របពេលដែលកម្ពុជាត្រៀមខ្លួនចាកចេញពីឋានៈ LDC។

**បញ្ហាប្រឈមទីពីរ គឺគម្លាតជំនាញ និងផលិតភាព។** កម្ពុជាសម្រេចបានលទ្ធផលល្អប្រសើរក្នុងការជំរុញដែលប្រើប្រាស់កម្លាំងពលកម្មខ្លាំង ប៉ុន្តែដំណាក់កាលបន្ទាប់នៃការពង្រឹងឧស្សាហកម្មនឹងតម្រូវឱ្យមានអ្នកបច្ចេកទេស វិស្វករឧស្សាហកម្ម បុគ្គលិកថែទាំ និងអ្នកបញ្ជាម៉ាស៊ីន ដែលអាចគាំទ្រដល់ប្រព័ន្ធស្វ័យប្រវត្តិកម្ម កម្មន្តសាលឌីជីថល និងដំណើរការផលិតកម្មដែលកាន់តែទំនើប។ បើគ្មានកំណើនផលិតភាពខ្លាំងជាងមុនទេ ការកើនឡើងនៃប្រាក់ឈ្នួលអាចនឹងធ្វើឱ្យសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជាធ្លាក់ចុះជាលំដាប់។

**បញ្ហាប្រឈមទីបី មកពីកត្តារាំងស្ទះផ្នែកថាមពល បរិស្ថាន និងចង្កោមឧស្សាហកម្ម។** សកម្មភាពផលិតកម្មវាយនភណ្ឌ ជាពិសេសក្នុងដំណាក់កាលជ្រលក់ពណ៌ និងការកែច្នៃសម្រេច គឺជាសកម្មភាពដែលប្រើប្រាស់ថាមពល និងទឹកក្នុងកម្រិតខ្ពស់ ព្រមទាំងអាចប៉ះពាល់យ៉ាងខ្លាំងចំពោះបរិស្ថាន។ កត្តារួមផ្សំមានដូចជា ថ្លៃដើមខ្ពស់នៃប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ លក្ខខណ្ឌតម្រូវផ្នែកបរិស្ថានកាន់តែតឹងរ៉ឹងពីអ្នកបញ្ជាទិញ និងភាពយឺតយ៉ាវក្នុងការរៀបចំដីឧស្សាហកម្មដែលមានហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ប្រកបដោយទំនុកចិត្ត សុទ្ធសឹងជាកត្តាជំរុញឱ្យវិនិយោគិនមានការរារែក។ បន្ថែមលើនេះ រោងចក្រវាយនភណ្ឌទាមទារនូវការបោះទុនយ៉ាងច្រើនសន្ធឹកសន្ធាប់ និងចាំបាច់ត្រូវមានខ្នាតផលិតកម្មធំ (Economies of Scale) ដើម្បីធានានូវលទ្ធភាពចំណេញ ខណៈដែលប្រព័ន្ធអេកូឡូស៊ីក្នុងវិស័យវាយនភណ្ឌបច្ចុប្បន្នរបស់កម្ពុជានៅមានកម្រិតនៅឡើយ បើធៀបនឹងដៃគូប្រកួតប្រជែងសំខាន់ៗ។

## កាលានុវត្តភាពដែលកំពុងលេចឡើង

ទោះបីជាមានហានិភ័យទាំងនេះក៏ដោយ កម្ពុជានៅតែមានឱកាសក្នុងការកែប្រែស្ថានភាពវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូបរបស់ខ្លួន។ ឱកាសសំខាន់បំផុតដែលបង្កើតឡើងដោយការចាកចេញពី LDC គឺការជំរុញលើទឹកចិត្តឱ្យ

មានការវិនិយោគលើឧស្សាហកម្មប្រតិគមន៍ (Backward Linkages) សម្រាប់ខ្សែច្រវាក់ផលិតកម្មវាយនភណ្ឌ និងការរក្សាបាននូវការអនុគ្រោះទីផ្សារតាមរយៈការប្រើប្រាស់វត្ថុធាតុដើម ដែលផលិតនៅក្នុងស្រុក។

ជាដំបូង ការផ្លាស់ប្តូរវិធានដើមកំណើតទំនិញបង្កើតឱ្យមានការលើកទឹកចិត្តយ៉ាងខ្លាំងសម្រាប់ការវិនិយោគផលិតកម្មវត្ថុធាតុដើម ជាពិសេសសម្រាប់ឧស្សាហកម្មប្រតិគមន៍។ រោងចក្រវាយនភណ្ឌ រោងចក្រជ្រលក់ពណ៌ និងរោងចក្រផលិតក្រណាត់សម្រេចដែលបានបង្កើតឡើងក្នុងស្រុក អាចផ្គត់ផ្គង់ដល់មូលដ្ឋានអ្នកនាំចេញសម្លៀកបំពាក់ដែលមានស្រាប់ ដែលនឹងកាន់តែត្រូវការក្រណាត់មានដើមកំណើតកម្ពុជា ដើម្បីរក្សាបាននូវការអនុគ្រោះពន្ធគយក្រោយឆ្នាំ២០២៩។

ទីពីរ កម្ពុជាមានវិសាលភាពសម្រាប់ការធ្វើទំនើបកម្មផលិតផលនៅក្នុងខ្សែច្រវាក់តម្លៃ GFT។ វិស័យនេះអាចវិវត្តន៍ជាបណ្តើរៗពីផលិតផលសម្លៀកបំពាក់ធម្មតា ទៅផលិតផលដែលមានភាពស្មុគស្មាញ និងមានតម្លៃខ្ពស់ជាងមុន។ ការធ្វើពិពិធកម្មដែលពាក់ព័ន្ធក៏អាចនឹងកើតឡើងជាបន្តបន្ទាប់ រួមមាន ការផលិតខ្សែលួសដែលមានស្រទាប់ការពារ និងការផលិតដែលពាក់ព័ន្ធនឹងគ្រឿងអេឡិចត្រូនិក ប៉ុន្តែអាទិភាពចំពោះមុខគឺការពង្រឹងការធ្វើទំនើបកម្មនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូបផ្ទាល់។

ទីបី កម្ពុជាអាចកែលម្អភាពទាក់ទាញរបស់ខ្លួនបន្ថែមទៀត តាមរយៈបរិយាកាសវិនិយោគដែលកាន់តែមានភាពប្រសើរឡើង។ ច្បាប់ស្តីពីការវិនិយោគថ្មី សេវាច្រកចេញចូលតែមួយសម្រាប់វិនិយោគិន និងការវិនិយោគធំៗ លើផ្លូវល្បឿនលឿន កំពង់ផែ និងមជ្ឈមណ្ឌលភស្តុភារ បានធ្វើឱ្យបរិយាកាស សម្រាប់ការវិនិយោគក្នុងវិស័យកម្មន្តសាលកាន់តែល្អជាងមុន។ ស្របពេលជាមួយគ្នានេះ កម្ពុជាមានគោលដៅបង្កើនចំណែកនៃថាមពលកកើតឡើងវិញឱ្យដល់ ៧០ ភាគរយ ត្រឹមឆ្នាំ ២០៣០ ដែលកើនពី ៦២ ភាគរយ ក្នុងឆ្នាំ២០២៥ ដោយមានការគាំទ្រពី ការវិនិយោគដែលបានអនុម័តក្នុងវិស័យថាមពលប្រមាណ ៥,៧៩ ពាន់លានដុល្លារអាម៉េរិក ចន្លោះឆ្នាំ២០២៤ និង ២០២៩។ ការរក្សាទុកថាមពលត្រូវបានកំណត់ជាអាទិភាពយុទ្ធសាស្ត្រ ដោយក្នុងនោះគម្រោងរក្សាទុកថាមពលក្នុងអាគុយ និងគម្រោងវារីអគ្គិសនីដែលបានអនុម័តរំពឹងថានឹងផ្តល់សមត្ថភាពសរុប ២,០០០ មេហ្គាវ៉ាត់។ វឌ្ឍនភាពទាំងនេះ ពង្រឹងជំហររបស់កម្ពុជាក្នុងនាមជាទីតាំងវិនិយោគដែលមានភាពប្រកួតប្រជែង និងកាន់តែមានភាពបៃតង សម្រាប់ការវិនិយោគលើដើមខ្សែច្រវាក់ផលិតកម្មវាយនភណ្ឌ Upstream និងការវិនិយោគលើវិស័យកម្មន្តសាលដែលមានតម្លៃខ្ពស់ជាងមុន។

## ការផ្តល់អនុសាសន៍គោលនយោបាយ

កម្ពុជាចាំបាច់ត្រូវឆ្លើយតបទៅនឹងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច និងលក្ខខណ្ឌពាណិជ្ជកម្មអន្តរជាតិដែលកាន់តែតឹងរ៉ឹង តាមរយៈយុទ្ធសាស្ត្រឧស្សាហកម្មដែលមានសង្គតិភាពខ្ពស់ ដើម្បីការពារសមិទ្ធផលនៃការនាំចេញនាពេលបច្ចុប្បន្ន ព្រមទាំងត្រៀមលក្ខណៈឱ្យវិស័យ GFT អាចឆ្លើយតបបានយ៉ាងមានប្រសិទ្ធភាពទៅនឹងវិធានដើមកំណើតទំនិញក្រោយឆ្នាំ២០២៩។ ក្នុងន័យនេះ ជម្រើសគោលនយោបាយអាទិភាពចំនួន ៥ ត្រូវបានកំណត់ដើម្បីជំរុញការផ្លាស់ប្តូររចនាសម្ព័ន្ធ រួមមាន៖ (១) ការអនុវត្តការបូកសរុបតម្រូវការរួម ដើម្បីប៉ាន់ស្មានបរិមាណអប្បបរមានៃការជានាទិញក្រណាត់ ក្នុងអំឡុងពេលអន្តរកាល (២) កំណត់ និងអភិវឌ្ឍតំបន់ឧស្សាហកម្មវាយនភណ្ឌ (៣) ពន្លឿនការអភិវឌ្ឍជំនាញ (៤) កាត់បន្ថយថ្លៃដឹកជញ្ជូន និងថ្លៃថាមពល និង (៥) ជំរុញការទូតពាណិជ្ជកម្មឱ្យកាន់តែសកម្ម តាមរយៈការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយដៃគូសំខាន់ៗ។

### ១. ការដាក់ចេញនូវការអនុវត្តការបូកសរុបតម្រូវការជាអាទិភាព

រាជរដ្ឋាភិបាល និងវិស័យឯកជន គួររួមគ្នាធ្វើការសិក្សាលទ្ធភាព ដើម្បីប៉ាន់ប្រមាណបរិមាណអប្បបរមានៃការជានាទិញក្រណាត់ ក្នុងអំឡុងពេលអន្តរកាលពី ៣ ទៅ ៥ ឆ្នាំ។ ចំណុចនេះមានសារៈសំខាន់ណាស់ក្នុងការបង្ហាញពីតម្រូវការទីផ្សារដ៏ច្បាស់លាស់មួយដល់វិនិយោគិនសក្តានុពលក្នុងវិស័យវាយនភណ្ឌ។ កម្ពុជាគួរគួបផ្សំនូវចំណុចនេះជាមួយនឹងកញ្ចប់លើកទឹកចិត្តចំគោលដៅសម្រាប់ «អ្នកវិនិយោគដំបូង» (First-movers) ដើម្បីទាក់ទាញវិនិយោគិនបង្គោលក្នុងខ្សែច្រវាក់ផលិតកម្មក្រណាត់ ការជ្រលក់ពណ៌ និងការកែច្នៃសម្រេច។ បើគ្មានទស្សនវិស័យច្បាស់លាស់លើតម្រូវការទីផ្សារទេ វិនិយោគិនធំៗក្នុងសកម្មភាពខ្សែច្រវាក់ផលិតកម្មផ្នែក Upstream ទំនងជានឹងមិនបោះទុនវិនិយោគនោះឡើយ។

### ២. ការកំណត់ និងអភិវឌ្ឍតំបន់ឧស្សាហកម្មវាយនភណ្ឌ

កម្ពុជាគួររៀបចំកំណត់តំបន់ "សួនឧស្សាហកម្មផ្នែកវាយនភណ្ឌដែលត្រូវបានអនុម័តជាមុន" (Pre-cleared Textile Parks) ដែលបំពាក់មកជាមួយនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មស្រេចស្រាប់ មានទំហំសមស្របសម្រាប់រោងចក្រខ្នាតធំ និងមានទីតាំងយុទ្ធសាស្ត្រក្បែរកំពង់ផែ បណ្តាញដឹកជញ្ជូន ព្រមទាំងសេវាប្រើប្រាស់ដែលមានស្ថិរភាពខ្ពស់។ តំបន់ឧស្សាហកម្មឯកទេសទាំងនេះ គួររួមបញ្ចូលនូវយន្តការរហ័ស (Fast-track) ក្នុងការផ្តល់អាជ្ញាប័ណ្ណផ្នែកបរិស្ថាន និងការគាំទ្របច្ចេកទេសសម្រាប់វិញ្ញាបនបត្រ ដែលស្របតាមស្តង់ដារតឹងរ៉ឹងរបស់សហភាពអឺរ៉ុប។ នេះគឺជាកត្តាចាំបាច់បំផុត ព្រោះវិនិយោគិនក្នុងផ្នែកវាយនភណ្ឌ និងការជ្រលក់ពណ៌ មិនត្រឹមតែត្រូវការដីសម្រាប់សាង

សង់ប៉ុណ្ណោះទេ ប៉ុន្តែពួកគេត្រូវការ "ប្រព័ន្ធអេកូឡូស៊ីឧស្សាហកម្ម" ដែលមានភាពច្បាស់លាស់នៃបទប្បញ្ញត្តិ និងសេវាកម្មរួម (Shared Services) ដើម្បីកាត់បន្ថយថ្លៃដើមដំបូងនៃការវិនិយោគ និងសម្រាលបន្ទុកនៃការអនុលោមតាមបទដ្ឋានអន្តរជាតិ។

### ៣. ពន្លឿនការអភិវឌ្ឍជំនាញសម្រាប់ការពង្រឹងឧស្សាហកម្ម

គោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) គួរត្រូវបានតម្រង់ទិសឡើងវិញឆ្ពោះទៅរកវិស្វកម្មឧស្សាហកម្ម ស្វ័យប្រវត្តិកម្ម និងការថែទាំម៉ាស៊ីន។ ភាពប្រកួតប្រជែងក្នុងដំណាក់កាលបន្ទាប់របស់កម្ពុជា នឹងពឹងផ្អែកកាន់តែតិចលើតែការដំឡើងដែលមានតម្លៃថោក និងពឹងផ្អែកកាន់តែខ្លាំងលើការដែលថាតើក្រុមហ៊ុនអាចដំណើរការម៉ាស៊ីនទំនើបៗ លើកកម្ពស់ផលិតភាព និងឈានទៅរកផលិតកម្មដែលមានតម្លៃខ្ពស់បានដែរឬទេ។ ដូច្នេះ ការពង្រីកជំនាញដែលពាក់ព័ន្ធនឹងឧស្សាហកម្ម មិនមែនគ្រាន់តែជាវិធានការគាំទ្រប៉ុណ្ណោះទេ ប៉ុន្តែគឺជាយុទ្ធសាស្ត្រស្នូលនៃភាពប្រកួតប្រជែង។

### ៤. កាត់បន្ថយថ្លៃដើមលើភស្តុភារ និងថាមពល

កម្ពុជាគួរតែបន្តជំរុញកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការកំពង់ផែ និងការធ្វើឌីជីថលូបនីយកម្មនីតិវិធីគយ សំដៅកាត់បន្ថយពេលវេលា និងថ្លៃដើមក្នុងកិច្ចសម្រួលពាណិជ្ជកម្ម។ ទន្ទឹមនឹងនេះ ការផ្តល់ភាពងាយស្រួលដល់បណ្តារោងចក្រក្នុងការដំឡើងប្រព័ន្ធថាមពលសូឡា (Solar Rooftop) គឺជាកត្តាចាំបាច់ ដើម្បីជួយកាត់បន្ថយចំណាយលើអគ្គិសនី និងឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវនៃផលិតកម្មបៃតង (RE100) របស់អ្នកបញ្ជាទិញ។ វិធានការទាំងនេះមានសារៈសំខាន់ជាយុទ្ធសាស្ត្រ សម្រាប់ការទាក់ទាញការវិនិយោគក្នុងខ្សែប្រវាក់ផ្គត់ផ្គង់ផ្នែកខាងលើ (Upstream) នៃវិស័យវាយនភណ្ឌ ដែលជាសកម្មភាពប្រើប្រាស់ថាមពលខ្លាំង ហើយស្ថិរភាពនៃថាមពល និងភាពប្រកួតប្រជែងនៃថ្លៃដើម គឺជាកត្តាសម្រេចចិត្តចម្បងក្នុងការជ្រើសរើសទីតាំងវិនិយោគ។

### ៥. ជំរុញការទូតពាណិជ្ជកម្ម និងការទាក់ទាញការវិនិយោគយុទ្ធសាស្ត្រ

កម្ពុជាគួរចាប់ផ្តើមការចរចាសម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាមួយដៃគូសំខាន់ៗ ដើម្បីកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងការអស់សុពលភាពនៃការអនុគ្រោះពន្ធសម្រាប់ក្រុមប្រទេស LDC។ ទន្ទឹមនឹងនេះ កម្ពុជាគួរប្រើប្រាស់គំនិតផ្តួចផ្តើម ខ្សែក្រវ៉ាត់ និងផ្លូវ (Belt and Road initiative) ឱ្យកាន់តែមានលក្ខណៈយុទ្ធសាស្ត្រ ដើម្បីទាក់ទាញការវិនិយោគពីប្រទេសចិនមកវិនិយោគលើខ្សែប្រវាក់ផ្គត់ផ្គង់សម្រាប់សកម្មភាពផ្នែក Upstream របស់វិស័យវាយនភណ្ឌ និងកាត់ដេរ (Upstream textile supply chains) ។ វិធីសាស្ត្រ Dual-track approach នេះមានសារៈសំខាន់ណាស់ ដោយកម្ពុជាត្រូវតែការពារការចូលទៅកាន់ទីផ្សារខាងក្រៅផង និងពង្រឹងសមត្ថភាពផលិតកម្មក្នុងស្រុកឱ្យកាន់តែស៊ីជម្រៅផង។

## សេចក្តីសន្និដ្ឋាន

វិស័យ GFT របស់កម្ពុជាបានបង្ហាញពីភាពធន់ ប៉ុន្តែភាពប្រកួតប្រជែងនាពេលអនាគតមិនអាចពឹងផ្អែកតែលើការដំឡើងដែលមានតម្លៃពលកម្មទាបតែមួយមុខនោះទេ។ ការផ្លាស់ប្តូរដែលពាក់ព័ន្ធនឹងការចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួច ជាពិសេសវិធានដើមកំណើតទំនិញដែលកាន់តែតឹងរ៉ឹងក្រោយឆ្នាំ២០២៩ ទាមទារឱ្យមានការឆ្លើយតបតាមរយៈគោលនយោបាយ ដែលប្រកបដោយលក្ខណៈសមាហរណកម្មខ្ពស់ជាងមុន។ កម្ពុជាគួរប្រើប្រាស់ដំណាក់កាលអន្តរកាលនេះ ដើម្បីពង្រឹងខ្សែប្រវាក់ផ្គត់ផ្គង់ក្នុងស្រុកឱ្យកាន់តែរឹងមាំ លើកកម្ពស់កម្រិតជំនាញ កាត់បន្ថយថ្លៃដើមឧស្សាហកម្ម និងធ្វើយ៉ាងណាឱ្យវិស័យនេះឈានទៅរកកំណើនប្រកបដោយផលិតភាព និងលក្ខណៈបៃតងជាងមុន។

## ឯកសារយោង


1. Council for the Development of Cambodia (CDC). 2021. *Law on Investment of the Kingdom of Cambodia.*

2. Council for the Development of Cambodia (CDC). 2023. *Handbook on Investing in Cambodia.*

3. International Trade Administration (2025). *Cambodia Country Commercial Guide: Energy, Power Generation Equipment.* https://www.trade.gov/country-commercial-guides/cambodia-energy-power-generation-equipment

4. Ministry of Mines and Energy (2026). *Cambodia Sustainable Energy Transition (CSET) Project (Draft version).* https://mme.gov.kh/fileadmin/careers/P510217_-CSET-LMP_DRAFT_07_JAN_2026.pdf?

## អំពីសេចក្តីសង្ខេបគោលនយោបាយនេះ

សេចក្តីសង្ខេបគោលនយោបាយនេះ ពិនិត្យលើទស្សនវិស័យសម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ ស្បែកជើង និងទំនិញធ្វើដំណើររបស់កម្ពុជាក្រោមសម្ពាធពន្ធគយ និងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDC)។ ខ្លឹមសារនេះបង្ហាញពីភាពធន់ជាបន្តបន្ទាប់នៃវិស័យនេះ ហានិភ័យពាក់ព័ន្ធនឹងតម្រូវការនៃវិធានដើមកំណើតទំនិញក្រោយឆ្នាំ២០២៩ និងសកម្មភាពគោលនយោបាយដែលចាំបាច់ ដើម្បីពង្រឹងភាពប្រកួតប្រជែង ទាក់ទាញការវិនិយោគលើខ្សែច្រវាក់ផលិតកម្មផ្នែកខាងលើ និងគាំទ្រដល់មូលដ្ឋានផលិតកម្មដែលមានសមាហរណកម្ម និងនិរន្តរភាពជាងមុន។

## សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមតិយោបល់ពីភាគីពាក់ព័ន្ធនានាដែលមានសារៈសំខាន់ក្នុងការរៀបចំឱ្យលេចចេញជាផ្លូវការនូវសេចក្តីសង្ខេបគោលនយោបាយនេះ។